# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៦៧៤......ប្រក.កសក

លិខិតចូល
ថ្ងៃទី១៩.....ខែ០៣....ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការបង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកប្រសប់

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បកចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង កែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៣៦១ ប្រក.កសក.បុ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១ :** បង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើមួយកន្លែងមានឈ្មោះថា ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកប្រសប់ មានទីតាំងស្ថិតក្នុងដែនដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្នុងឃុំជ្រោយបន្ទាយ ឃុំសាប និង ឃុំព្រែកប្រសប់ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ ។

**ប្រការ ២ :** ប្រកាសនេះមានគោលបំណង :

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់អភិវឌ្ឍប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ច សង្គម និង បរិស្ថាន
- អភិវឌ្ឍចំណេះដឹងបច្ចេកទេសដាំឈើ បំផុសការចូលរួមដាំឈើ និង ផ្តល់ការងារធ្វើដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដើម្បីធ្វើជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃដាំ និងអភិវឌ្ឍជីវចម្រុះ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ ដោយបង្កើនផលិតផលឈើពីព្រៃដាំ
- ចូលរួមចំណែកក្នុងយន្តការអភិវឌ្ឍស្អាត ឬយន្តការផ្សេងៗទៀតដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី និងទប់ស្កាត់បម្រែបម្រួលអាកាសធាតុ
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និង អភិវឌ្ឍសហគមន៍មូលដ្ឋាន។

**ប្រការ ៣ :** ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើព្រែកប្រសប់ មានផ្ទៃក្រឡាសរុប ៣០.១៦៤ (សាមសិបពាន់មួយរយហុកសិបបួន) ហិកតា ដូចមានផែនទីមាត្រដ្ឋាន ១:១១០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចនិយាមកា:

A ( 595 732, 1401 103 ), B ( 605 206, 1401 206 ),C ( 605 443, 1381 448 ), D (610 264, 1368 961 ),

E ( 605 522, 1367 459 ), F ( 600 780, 1372 122 ), G ( 595 959, 1378 603 ), H ( 594 853, 1381 685 )

I ( 589 399, 1383 977 ), J ( 589 715, 1388 245 ), K ( 595 564, 1389 509 ) ។

**ប្រការ ៤:** ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើព្រែកប្រសប ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងមានភារកិច្ចដូចតទៅ៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ និង ធ្វើការបណ្តុះកូនឈើ ដាំឈើ ថែរក្សាការពារ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- សហការជាមួយដៃគូអភិវឌ្ឍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ ផលិត កែច្នៃ និង ប្រមូលផល អនុផលចម្ការព្រៃដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផលិត កែច្នៃ និង ផ្តល់មុខរបរដល់សហគមន៍មូលដ្ឋាន
- កៀរគរ ទាក់ទាញ ការចូលរួមគាំទ្រ និង ទទួលជំនួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋានជាតិ និង អន្តរជាតិ ។

**ប្រការ ៥ :** ដំណើរការ និង ការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៦ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធ និង ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ ៦ ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តក្រចេះ
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

## ផែនទី ទីតាំងស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ព្រែកប្រសប់ ស្ថិតក្នុងស្រុកព្រែកប្រសប់ ខេត្តក្រចេះ

